ផ្សារមូលបត្រកម្ពុជា
CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ......០៧៦/២០........

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ អង្គារ ១៤ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

## ការចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម

## របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់និងផ្សារមូលបត្រកម្ពុជា បានប្រារព្ធពិធីចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។ សញ្ញាបណ្ណសាជីវកម្មនេះមានឈ្មោះថា “សញ្ញាបណ្ណសាជីវកម្មប្រាសាក់” ជាសញ្ញាបណ្ណមានបុគ្គលធានា ដែលមានទំហំសរុបចំនួន១២៧,២ប៊ីលានរៀល (ប្រមាណ ៣១,៨ លានដុល្លារអាមេរិក) ជាមួយអត្រាគូប៉ុង ៧,៥% ក្នុងមួយឆ្នាំ និងមានឥណប្រតិទានរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

នៅក្នុងពិធីនេះ **ឯកឧត្តម ស៊ូ សុជាតិ** បានគូសបញ្ជាក់ថា ការសម្រេចបានជោគជ័យនូវការបោះផ្សាយ និងចុះបញ្ជីលក់មូលបត្របំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ក្នុងស្ថានភាពបច្ចុប្បន្ននេះ បានបង្ហាញអោយឃើញថា វិនិយោគិនមានទំនុកចិត្តខ្លាំងចំពោះភាពរឹងមាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ក៏ដូចជាមានទំនុកចិត្តចំពោះកិច្ចការងារត្រួតពិនិត្យរបស់ គ.ម.ក. និងធនាគារជាតិនៃកម្ពុជា ហើយក៏បង្ហាញផងដែរពីទំនុកចិត្តដែលកាន់តែមានច្រើនឡើងចំពោះផ្សារមូលបត្រកម្ពុជា។ បន្ថែមពីលើនេះ **ឯកឧត្តម ហុង សុហួរ** អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក៏បានលើកឡើងផងដែរថា គិតត្រឹមថ្ងៃចុះបញ្ជីនេះ ផ្សារមូលបត្រកម្ពុជាមានក្រុមហ៊ុន ចុះបញ្ជីសរុបចំនួន ១១ ដែលបានប្រមូលទុនពីទីផ្សារមូលបត្រសរុបប្រមាណជាង ២២៣ លានដុល្លារ។ ហើយការទទួលបានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុលចំនួន ៣ក្រុមហ៊ុន ក្នុងរយៈពេលត្រឹមតែ ៥ខែដំបូងនៅឆ្នាំ២០២០ និងការរំពឹងថានឹងមានការចុះបញ្ជីក្រុមហ៊ុននាពេលអនាគតដ៏ខ្លីខាងមុខជាបន្តបន្ទាប់ទៀត កំពុងបង្ហាញពីភាពរីកចម្រើនល្អគួរលាស់ទៅមុខនៃទីផ្សារមូលបត្រកម្ពុជា ដែលអាចក្លាយជាប្រភពហិរញ្ញប្បទានចម្បងមួយសម្រាប់អាជីវកម្មក្នុងស្រុកនានា និងជាទីកន្លែងវិនិយោគដ៏គួរអោយចាប់អារម្មណ៍សម្រាប់សាធារណជនដែលជាវិនិយោគិន ។ដោយឡែក **លោក ហេង ម៉ុមករា** អគ្គនាយករងត្រួតពិនិត្យ តំណាងនៃធនាគារ

ជាតិនៃកម្ពុជា ក៏បានបញ្ជាក់ដែរថា ការបោះផ្សាយមូលបត្របំណុលជាសាធារណៈ ជាផ្នែកមួយជម្រុញដល់ដំណើរការទីផ្សារមូលធននៅកម្ពុជាស្រប តាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ របស់ រាជរដ្ឋាភិបាលកម្ពុជា។ ចំពោះការបោះផ្សាយមូលបត្របំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ គឺជាផ្នែកមួយនៃការធ្វើពិពិធកម្មប្រភពមូលនិធិរបស់គ្រឹះស្ថានបន្ថែម លើប្រភពមូលនិធិជាប្រាក់បញ្ញើរបស់អតិថិជន និងការខ្ចីមូលនិធិពីក្រៅប្រទេស ហើយការបោះផ្សាយនេះក៏ជាជម្រើស ផលិតផលថ្មីមួយទៀតសម្រាប់អតិថិជននិង វិនិយោគិនផងដែរ។ រីឯ**លោក ស៊ឹម សេនាជាតិ** ប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ក៏បានលើកឡើងដែរថា ការបោះផ្សាយមូលបត្របំណុលនេះផ្តល់អោយប្រាសាក់នូវប្រភពទុនរយៈពេលវែងថ្មីមួយទៀត ដែលអនុញ្ញាតអោយប្រាសាក់ពង្រីកសក្តានុពលរបស់ខ្លួនបន្ថែមទៀត ក្នុងការផ្តល់ឥណទានជាប្រាក់រៀលជូនប្រជាជនកម្ពុជានិងផ្តល់ជូនគុណវុឌ្ឍយ៉ាងពេញលេញដល់ប្រាសាក់ក្នុងនាមជាគ្រឹះស្ថានដែលមានស្ថិរភាពហិរញ្ញវត្ថុដ៏រឹងមាំ មានតម្លាភាពហិរញ្ញវត្ថុ និងអនុវត្តបានពេញលេញតាមបទប្បញ្ញត្តិនានា។

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង÷

លោក ហៃ លីដេត

ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីនិងផ្តល់ព័ត៌មាន

អ៊ីម៉ែល÷ lideth.hay@csx.com.kh